01722126

F83/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អនុស្សរណៈអន្តរការិយាល័យ

**ផ្ញើពី:** **ឯកឧត្តម គង់ ស្រ៊ីម** ប្រធានអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២៣

**ផ្ញើជូន:** លោក **គង់ សំអុន** សហមេធាវីការពារក្ដីជាតិ
លោកស្រី **Anta GUISSÉ** សហមេធាវីការពារក្ដីអន្តរជាតិ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-May-2023, 11:08
CMS/CFO: Sann Rada

**ចម្លងជូន:** **ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**
លោកជំទាវ **ជា លាង** សហព្រះរាជអាជ្ញាជាតិ
លោកស្រី Fergal GAYNOR សហព្រះរាជអាជ្ញាអន្តរជាតិ(បម្រុង)
**លោក ពេជ អង្គ** សហមេធាវីនាំមុខជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
**លោកស្រី** Falguni DEBNATH សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
**ឯកឧត្តម ក្រាញ់ តូនី** ប្រធានស្ដីទីការិយាល័យរដ្ឋបាល
**ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល**

**កម្មវត្ថុ:** **ការឆ្លើយតបទៅនឹងសេចក្ដីសង្ខេបរបស់សហមេធាវីការពារក្ដីបន្ទាប់ពីការផ្ទេរទណ្ឌិត ខៀវ សំផន ទៅពន្ធនាគារខេត្តកណ្ដាល និងការឆ្លើយតបរបស់ការិយាល័យរដ្ឋបាលចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២២**

រំលឹកថា នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២៣ អង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកាដែលមានសំអាងហេតុពេញលេញក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន ជាភាសាខ្មែរ និងអង់គ្លេស[1]។

[1] ការបកប្រែភាសាបារាំងត្រូវបានជូនដំណឹងនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៣ (F76)។

នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២៣ ខៀវ សំផន ត្រូវបានផ្ទេរទៅពន្ធនាគារខេត្តកណ្តាល តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា[2]។

**កត់សម្គាល់ថា** នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ ការិយាល័យរដ្ឋបាលបានឆ្លើយតប[3]ទៅនឹងសំណើរបស់អង្គជំនុំជម្រះស្នើសុំព័ត៌មានពាក់ព័ន្ធទៅនឹងការអនុម័តក្របខ័ណ្ឌការងារដែលរៀបរាប់លម្អិតអំពីយន្តការកេរដំណែលដែលត្រូវអនុវត្តជាក់ស្តែងនូវតួនាទីរបស់ខ្លួនក្នុងការគ្រប់គ្រងការអនុវត្តន៍ការដាក់ទោសបញ្ចូលគ្នាទៅលើ ខៀវ សំផន ព្រមទាំងការតាមដានលក្ខខណ្ឌរបស់គាត់ខណៈពេលអនុវត្តទោសទាំងនោះ[4]។ បន្ទាប់ពីការផ្ទេរនេះ ខៀវ សំផន ត្រូវបានដាក់ឱ្យស្ថិតក្រោមយុត្តាធិការទាំងស្រុងនៃអគ្គនាយកដ្ឋានពន្ធនាគារជាតិយោងតាមការិយាល័យរដ្ឋបាល[5]។ ការិយាល័យរដ្ឋបាលបានបំភ្លឺបន្ថែមទៀតថា កិច្ចព្រមព្រៀងបន្ថែមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀងបន្ថែម") បានផ្តល់ឱ្យ អ.វ.ត.ក. នូវមុខនាទីកេរដំណែលមួយចំនួន រួមទាំង "ការត្រួតពិនិត្យការអនុវត្តន៍ទោស" និង "ការតាមដានការព្យាបាលទណ្ឌិត"[6]។

នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣ សហមេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីសង្កេតដែលលើកឡើងអំពីការលំបាកដែលគាត់ពុំអាច*ក្នុងចំណោមនោះ* (i) ពិនិត្យឱ្យបានពេញលេញលើសាលដីកា ពីព្រោះ

---

[2] សំណើសុំផ្ទេរពិរុទ្ធជន ខៀវ សំផន (F82) ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២៣។ មុនការផ្ទេរ សហព្រះរាជអាជ្ញាបានពិភាក្សាមួយប្រធានអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ និងទទួលការបញ្ជាក់ពីការិយាល័យរដ្ឋបាលអំពីនិរន្តរភាពនៃការជួយសម្រួលដល់ការរៀបចំផ្នែកវេជ្ជសាស្ត្រដល់ ខៀវ សំផន ជាមួយមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ក្នុងការទទួលបានការពិនិត្យជាប្រចាំ និងការផ្តល់អ្នកជួយថែទាំបន្ទាប់ពីការផ្ទេរ ខៀវ សំផន ទៅពន្ធនាគារខេត្តកណ្តាល *យោងទៅលើសំណើសុំការអនុវត្តន៍ទោស* (F80) ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២៣។ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើលក្ខខណ្ឌនៃការអនុវត្តន៍ទោស (F81) ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២៣។ សំណើសុំផ្ទេរពិរុទ្ធជន ខៀវ សំផន (F82) ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២៣។

[3] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូលស្នើសុំព័ត៌មានពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យការអនុវត្តន៍ទោសទណ្ឌិត ខៀវ សំផន (F77/1/2) ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ ("ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល")។

[4] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌឃុំខ្លួនដែលបានរៀបចំ (F77/1/1) ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២៣។

[5] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២។

[6] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៣។

គាត់ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រយួរដៃក្នុងពន្ធនាគារខេត្តកណ្តាល ដែលគាត់ចាំបាច់ត្រូវពង្រីកអក្សរធំៗពិនិត្យមើលសាលដីកា ដោយសារគាត់មានបញ្ហាភ្នែក (ii) ទំនាក់ទំនងផ្ទាល់ និងដោយសម្ងាត់ជាមួយសហមេធាវីការពារក្តីអន្តរជាតិរបស់គាត់ដើម្បីទទួលបានការប្រឹក្សាផ្នែកច្បាប់ក្នុងការរៀបចំលទ្ធភាពបណ្តឹងសើរើលើសាលដីកាស្ថាពរស្របតាមវិធាន ១១២ នៃវិធានផ្ទៃក្នុង[7]។ សហមេធាវីការពារក្តីស្នើសុំការិយាល័យរដ្ឋបាល ឬអង្គជំនុំជម្រះតុលាការកំពូលកំណត់ថាតើ ខៀវ សំផន អាចប្រើប្រាស់កុំព្យូទ័រនោះបានដូចម្តេច ព្រមទាំងនីតិវិធីដែលអនុញ្ញាតឱ្យសហមេធាវីការពារក្តីជាតិចូលសួរសុខទុក្ខកូនក្តីរបស់ខ្លួនយ៉ាងដូចម្តេចក្នុងលក្ខខណ្ឌចាំបាច់[8]។ ពុំមានការបង្ហាញច្បាស់លាស់ពាក់ព័ន្ធទៅនឹងស្ថាប័នសមស្របក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើង និងការជាប់ពាក់ព័ន្ធ[9]។

រំលឹកថា សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងសិទ្ធិរបស់ ខៀវ សំផន ក្នុងការអាន និងពិនិត្យសាលដីកានោះ ប៉ុន្តែបានឆ្លើយតបថា ខុសពីបណ្តឹងសាទុក្ខធម្មតាលើសាលក្រម បណ្តឹងសើរើតាមវិធាន ១១២ គឺជាវិធីសាស្ត្រខុសពីធម្មតាដែលជាចម្បងពុំជាប់ពាក់ព័ន្ធទៅនឹងការវិភាគលម្អិតលើសាលដីកានោះទេ[10]។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា ខៀវ សំផន គឺស្ថិតក្រោមយុត្តាធិការទាំងស្រុងនៃអគ្គនាយកដ្ឋានពន្ធនាគារជាតិ និងតម្រូវឱ្យគោរពតាមបទបញ្ជាពន្ធនាគារពាក់ព័ន្ធទៅនឹងការប្រើប្រាស់កុំព្យូទ័រយួរដៃ ឬឧបករណ៍ប្រើប្រាស់អេឡិចត្រូនិចផ្សេងៗ។ សហព្រះរាជអាជ្ញាបានអះអាងថា សហមេធាវីការពារក្តីពុំបានបង្ហាញការរំលោភបំពានសិទ្ធិទូទៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សសម្រាប់ជនជាប់ឃុំ ក្នុងការប្រើប្រាស់កុំព្យូទ័រនោះ និងពុំបានបង្ហាញហានិភ័យខ្ពស់ប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីច្បាប់ ប្រសិនបើគាត់ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នោះឡើយ[11]។ សេចក្តីសង្កេតរបស់គាត់ពុំបានបង្ហាញថាតើ មានកិច្ចខិតខំប្រឹងប្រែងណាមួយត្រូវបានធ្វើឡើង ដែរ ឬយ៉ាងណា ដើម្បីដោះស្រាយបញ្ហាតាមរយៈមន្ត្រីដែលត្រូវបានចាត់តាំងដោយការិយាល័យរដ្ឋបាលក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹងការឃុំខ្លួន ខៀវ សំផន ឡើយ[12]។

---

[7] សេចក្តីសង្កេតបន្ទាប់ពីផ្ទេរលោក ខៀវ សំផន ទៅឃុំឃាំងនៅពន្ធនាគារខេត្តកណ្តាល ចម្លើយតបរបស់រដ្ឋបាលតុលាការចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ (ជូនដំណឹងថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០២៣) (F83)។

("សេចក្តីសង្កេតរបស់ ខៀវ សំផន") កថាខណ្ឌ ៥-៩ យោងទៅលើការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល។

[8] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ១២។

[9] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ១៣-១៦។

[10] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេតរបស់ ខៀវ សំផន បន្ទាប់ពីការផ្ទេរទៅពន្ធនាគារខេត្តកណ្តាល ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេត") ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២៣ កថាខណ្ឌ ៣, ៩-១០។

[11] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេត កថាខណ្ឌ ៦។

[12] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេត កថាខណ្ឌ ៧-៨, ១២។

តាមសេចក្តីសង្កេតដំបូងឃើញថា ភាគីត្រូវបានរំលឹកថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន ត្រូវបានជំនុំជម្រះចប់សព្វគ្រប់ និងថា អាណត្តិនៃបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានអនុវត្តពេញលេញស្របតាមកម្រងឯកសារច្បាប់ពាក់ព័ន្ធរបស់ អ.វ.ត.ក. ។ បន្ថែមលើនេះ បទប្បញ្ញត្តិដែលកំណត់អំពីការអនុវត្តន៍ទោសត្រូវបានគោរពតាម។ ដូច្នេះ ខៀវ សំផន បច្ចុប្បន្នកំពុងអនុវត្តទោសរបស់ខ្លួនជាប់ពន្ធនាគារអស់មួយជីវិតក្នុងពន្ធនាគារខេត្តកណ្តាល។

ជាការឆ្លើយតបទៅនឹងសេចក្តីសង្កេតជាក់លាក់របស់មេធាវីការពារក្តីថា ពុំមានការរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន បានកើតឡើង ឬត្រូវបានបង្ហាញជាសត្យានុម័តកន្លងមកពាក់ព័ន្ធនឹងការដែលគាត់ពុំអាចប្រើប្រាស់កុំព្យូទ័រ ឬកង្វះលក្ខខណ្ឌសមស្របសម្រាប់ការទំនាក់ទំនង ឬជួបជាមួយមេធាវីការពារក្តីរបស់ខ្លួនឡើយ។ ខៀវ សំផន ត្រូវស្ថិតក្រោមយុត្តាធិការទាំងស្រុងរបស់អគ្គនាយកដ្ឋានពន្ធនាគារជាតិ និងពន្ធនាគារខេត្តកណ្តាល ដូចបានបញ្ជាក់ដោយសហព្រះរាជអាជ្ញា និងដូច្នេះ តម្រូវឱ្យគោរពតាមបទបញ្ជាពន្ធនាគារដែលកំណត់អំពីការប្រើប្រាស់កុំព្យូទ័រយួរដៃ ឬឧបករណ៍ប្រើប្រាស់អេឡិចត្រូនិកផ្សេងៗ។ សហមេធាវីការពារក្តីពុំបានបង្ហាញថា ការប៉ុនប៉ងណាមួយក្នុងការទាក់ទងជាមួយអគ្គនាយកដ្ឋានពន្ធនាគារជាតិ និង/ឬអាជ្ញាធរក្នុងពន្ធនាគារខេត្តកណ្តាលសម្រាប់រកដំណោះស្រាយត្រូវបានធ្វើឡើង។ បន្ថែមលើនេះ ការផ្តល់ឯកសារដែលអាចអានបានសម្រាប់ ខៀវ សំផន គឺជាមុខនាទីដែលមេធាវីគប្បីធ្វើ និងពុំមែនជាការរំលោភបំពានលើសិទ្ធិរបស់មេធាវីការពារក្តីនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំអាងហេតុរបស់សហព្រះរាជអាជ្ញាមានលក្ខណៈត្រឹមត្រូវថា សហមេធាវីការពារក្តីជាតិ ដែលប្រើប្រាស់ភាសាខ្មែរ និងអាចពិនិត្យភស្តុតាងដែលបានយោងក្នុងសាលដីកានោះ អាចជួប ខៀវ សំផន ក្នុងពន្ធនាគារ និងផ្តល់ឱ្យគាត់នូវឯកសារចាំបាច់ និងពិភាក្សាពន្យល់សាលដីកានោះ[13] និងថា ខៀវ សំផន អាចជួបមេធាវីការពារក្តីរបស់គាត់ពេញលេញ ដែលអាចទំនាក់ទំនងដោយសម្ងាត់ក្នុងបន្ទប់គាត់នៅចន្លោះពីម៉ោង ៨ និង ០០ នាទី ដល់ ១១ និង ០០ នាទីព្រឹក និងម៉ោង ២ និង ០០ នាទី ដល់ ៥ និង ០០ នាទីល្ងាច ប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍[14]។ ពុំមានការជំទាស់ណាមួយទៅលើការលើកឡើងនេះឡើយ។

[13] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេត កថាខណ្ឌ ៦។

[14] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេត កថាខណ្ឌ ៧-៨, ១២។

បើទោះបីជាសេចក្តីសង្កេតរបស់មេធាវីការពារក្តីចង់សំដៅទៅលើលទ្ធភាពនៃបណ្តឹងសើរើតាមវិធាន ១១២ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សេចក្តីសង្កេតនេះត្រូវបានចាត់ទុកថាត្រឹមតែជាការបង្ការទុកជាមុន ពីព្រោះពុំមានការបង្ហាញអត្តសញ្ញាណនៃការរំលោភបំពានដែលបានចោទប្រកាន់នោះឡើយ។ ដូច្នេះ សេចក្តីសង្កេតនេះពុំតម្រូវឱ្យមានការពិចារណា។

ពាក់ព័ន្ធទៅនឹងការលើកឡើងរបស់សហមេធាវីការពារក្តីដែលថា ពុំមានភាពច្បាស់លាស់គ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងស្ថាប័នសមស្របក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើង និងការជាប់ពាក់ព័ន្ធនោះ[15] សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះតុលាការកំពូលនៅតែមានអត្ថិភាព និងបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មដូចបានរៀបរាប់ក្នុងកិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងថា ជាការពុំសមស្របក្នុងការចោទសួរថាតើ អង្គជំនុំជម្រះតុលាការកំពូលជាស្ថាប័នសមស្របសម្រាប់ដោះស្រាយការរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន ដែលបានចោទប្រកាន់នោះ[16]។ គួរកត់សម្គាល់ កិច្ចព្រមព្រៀងបន្ថែមនេះ ដូចបានបញ្ជាក់ដោយការិយាល័យរដ្ឋបាលបានផ្តល់ឱ្យ អ.វ.ត.ក. នូវតួនាទីមួយចំនួនដែលនៅសេសសល់ រួមទាំង*ក្នុងចំណោមនោះ* "ការត្រួតពិនិត្យលើការអនុវត្តន៍ទោស" និង"ការតាមដានការប្រព្រឹត្តលើទណ្ឌិត"[17]។ តួនាទីបច្ចុប្បន្នទាំងនេះមានអត្ថិភាពសម្រាប់រយៈពេលបីឆ្នាំដំបូង។ អង្គជំនុំជម្រះតុលាការកំពូលនៅតែមានអត្ថិភាព និងត្រូវបំពេញតួនាទីដែលនៅសេសសល់ប៉ុណ្ណោះ ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

អាស្រ័យហេតុនេះ សេចក្តីសង្កេតរបស់សហមេធាវីការពារក្តីពុំមានមូលដ្ឋានគ្រប់គ្រាន់តម្រូវឱ្យមានចំណាត់ការពីអង្គជំនុំជម្រះតុលាការកំពូល និងដូច្នេះ ពុំអាចទទួលយកបាន។

---

[15] សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ១៣-១៦។

[16] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសង្កេត កថាខណ្ឌ ៣, ១១-១២។

[17] ការឆ្លើយតបរបស់វិយាល័យរដ្ឋបាល កថាខណ្ឌ ៣។